ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

អគ្គនាយកដ្ឋានពន្ធដារ

លេខ...១៨០៩៤.....អពដ

L202110140308 | TD2804

ថ្ងៃអង្គារ ១២រោច ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ២០២១

# សេចក្តីណែនាំ

## ស្តីពី

## ការវាយតម្លៃ និងប្រកាសខ្លួនជាគ្រឹះស្ថានហិរញ្ញវត្ថុដែលមានកាតព្វកិច្ចរាយការណ៍ និងមិនមានកាតព្វកិច្ចរាយការណ៍នូវព័ត៌មានគណនីជនជាតិអាមេរិក ក្រោមកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលសហរដ្ឋអាមេរិក ដើម្បីធ្វើឱ្យប្រសើរឡើងនូវអនុលោមភាពពន្ធអន្តរជាតិ និងអនុវត្តច្បាប់ស្តីពីអនុលោមភាពពន្ធចំពោះគណនីក្រៅប្រទេសរបស់អាមេរិក

អនុលោមតាមកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលសហរដ្ឋអាមេរិកដើម្បីធ្វើឱ្យប្រសើរឡើងនូវអនុលោមភាពពន្ធអន្តរជាតិ និងអនុវត្តច្បាប់ស្តីពីអនុលោមភាពពន្ធចំពោះគណនីក្រៅប្រទេសរបស់អាមេរិក (កិច្ចព្រមព្រៀង FATCA) ប្រកាសលេខ១៤៥៩ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្តីពីការអនុវត្តកិច្ចព្រមព្រៀង FATCA និងក្នុងគោលបំណងកំណត់ឱ្យបានច្បាស់លាស់អំពីការវាយតម្លៃ និងប្រកាសខ្លួនជាគ្រឹះស្ថានហិរញ្ញវត្ថុដែលមានកាតព្វកិច្ចរាយការណ៍ និងមិនមានកាតព្វកិច្ចរាយការណ៍នូវព័ត៌មានគណនីជនជាតិអាមេរិក អគ្គនាយកដ្ឋានពន្ធដារ សូមធ្វើការណែនាំដល់គ្រឹះស្ថានហិរញ្ញវត្ថុ ដូចខាងក្រោម÷

១) គ្រឹះស្ថានហិរញ្ញវត្ថុត្រូវពិនិត្យ និងសិក្សាឱ្យបានច្បាស់លាស់អំពីកិច្ចព្រមព្រៀង FATCA ជាពិសេសលើលក្ខណវិនិច្ឆ័យដូចមានចែងក្នុងឧបសម្ព័ន្ធទី២ នៃកិច្ចព្រមព្រៀងនេះ និងសេចក្តីសង្ខេបស្តីពីការវាយតម្លៃខ្លួនជាគ្រឹះស្ថានហិរញ្ញវត្ថុដែលមិនមានកាតព្វកិច្ចរាយការណ៍ ដូចមានជូនភ្ជាប់មកជាមួយ ដើម្បីបញ្ជាក់ថាជាគ្រឹះស្ថានហិរញ្ញវត្ថុដែលមានកាតព្វកិច្ចរាយការណ៍ និងមិនមានកាតព្វកិច្ចរាយការណ៍នូវព័ត៌មានគណនីជនជាតិអាមេរិក មុនពេលធ្វើការចុះបញ្ជីតាមប្រព័ន្ធចុះបញ្ជីអនឡាញ FATCA។

២) ចំពោះ គ្រឹះស្ថានហិរញ្ញវត្ថុដែលបានពិនិត្យ និងវាយតម្លៃខ្លួនឃើញថាជាគ្រឹះស្ថានហិរញ្ញវត្ថុដែលមានកាតព្វកិច្ចរាយការណ៍នូវព័ត៌មានគណនីជនជាតិអាមេរិក គ្រឹះស្ថានហិរញ្ញវត្ថុនោះត្រូវចុះបញ្ជីតាមប្រព័ន្ធចុះបញ្ជីអនឡាញ FATCA និងអនុវត្តតាមកាតព្វកិច្ចនានាដូចមានចែងក្នុងប្រកាសលេខ១៤៥៩ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការអនុវត្តកិច្ចព្រមព្រៀង FATCA។

៣) ចំពោះ គ្រឹះស្ថានហិរញ្ញវត្ថុដែលបានពិនិត្យ និងវាយតម្លៃខ្លួនឃើញថាជាគ្រឹះស្ថានហិរញ្ញវត្ថុដែលមិនមានកាតព្វកិច្ចរាយការណ៍នូវព័ត៌មានគណនីជនជាតិអាមេរិក គ្រឹះស្ថានហិរញ្ញវត្ថុនោះត្រូវដាក់លិខិតជាលាយលក្ខណ៍អក្សរស្តីពីការវាយតម្លៃ និងប្រកាសខ្លួនជាគ្រឹះស្ថានហិរញ្ញវត្ថុដែលមិនមានកាតព្វកិច្ចរាយការណ៍ ដោយមានភ្ជាប់មកជាមួយនូវឯកសារគាំទ្រមកកាន់អគ្គនាយកដ្ឋានពន្ធដារ។ អគ្គនាយកដ្ឋានពន្ធដារនឹងធ្វើការពិនិត្យផ្ទៀងផ្ទាត់ជាមួយលក្ខណវិនិច្ឆ័យដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើ។



អគារលេខ ... អគារតេជោមហាវិថី សហព័ន្ធរុស្សី (១១០) និងម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (+855) 23 886 708 / ទូរសារ: (+855) 23 886 700, E-mail: gdt@tax.gov.kh, Website: www.tax.gov.kh

L202110140308 | TD2804

៤) ចំពោះ គ្រឹះស្ថានហិរញ្ញវត្ថុបានពិនិត្យ និងសិក្សានូវបទប្បញ្ញត្តិដូចមានចែងក្នុងចំណុចទី១ ខាងលើ ប៉ុន្តែនៅពុំទាន់អាចវាយតម្លៃបានថាខ្លួនជាគ្រឹះស្ថានហិរញ្ញវត្ថុដែលមានកាតព្វកិច្ចរាយការណ៍ ឬមិនមានកាតព្វកិច្ចរាយការណ៍នូវព័ត៌មានគណនីជនជាតិអាមេរិក គ្រឹះស្ថានហិរញ្ញវត្ថុអាចធ្វើការទំនាក់ទំនងផ្ទាល់មកការិយាល័យផ្លាស់ប្តូរព័ត៌មាន នៃនាយកដ្ឋាននីតិកម្ម គោលនយោបាយសារពើពន្ធ និងសហប្រតិបត្តិការពន្ធដារអន្តរជាតិ ដើម្បីផ្តល់ការប្រឹក្សាយោបល់អំពីស្ថានភាពរបស់គ្រឹះស្ថានហិរញ្ញវត្ថុ ឬតាមរយៈទូរសព្ទលេខ÷ ០២៣ ៨៨៣ ៧២៧។

៥) ក្នុងករណី គ្រឹះស្ថានហិរញ្ញវត្ថុដែលមិនមានកាតព្វកិច្ចរាយការណ៍មានការកែប្រែស្ថានភាព ឬលក្ខខណ្ឌណាមួយ ដែលនាំឱ្យគ្រឹះស្ថានហិរញ្ញវត្ថុនោះក្លាយទៅជាគ្រឹះស្ថានហិរញ្ញវត្ថុដែលមានកាតព្វកិច្ចរាយការណ៍ គ្រឹះស្ថានហិរញ្ញវត្ថុនោះត្រូវចុះបញ្ជីតាមប្រព័ន្ធចុះបញ្ជីអនឡាញ FATCA និងអនុវត្តតាមកាតព្វកិច្ចនានាដូចមានចែងក្នុងប្រកាសលេខ១៤៥៩ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការអនុវត្តកិច្ចព្រមព្រៀង FATCA។

អគ្គនាយកដ្ឋានពន្ធដារសង្ឃឹមជឿជាក់យ៉ាងមុតមាំថា គ្រឹះស្ថានហិរញ្ញវត្ថុទាំងអស់នឹងចូលរួមអនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំនេះប្រកបដោយការទទួលខុសត្រូវ និងប្រសិទ្ធភាពខ្ពស់។

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី

ប្រតិភូរាជរដ្ឋាភិបាល

ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ

គង់ វិបុល

# Brief on Self-Assessment for Non-Reporting Cambodian Financial Institution

To be qualified as a Non-Reporting Cambodian Financial Institution, you must be one, which specifically identified as such in Annex II of the Agreement between the Government of the United States of America and the Royal Government of Cambodia to Improve International Tax Compliance and to Implement FATCA (IGA).

**A. An Exempt Beneficial Owner; or**

**B. A Deemed Compliant Foreign Financial Institution**

A Non-Reporting Cambodian Financial Institution is not required to register with the U.S. Internal Revenue Service (IRS) to obtain a Global Intermediary Identification Number (GIIN) or carry out the due diligence and reporting obligations in relation to any Financial Accounts that it may maintain under the IGA.

A Financial Institution shall self-assess whether it meets these criteria and maintain appropriate records to support its assessment.

**A. Exempt Beneficial Owner**

You may qualified as a Non-Reporting Financial Institutions If you are one of the following Exempt Beneficial Owners below:

**1. Governmental Entity**

The government of Cambodia, any political subdivision of Cambodia including local authority, or any wholly owned agency or instrumentality of Cambodia. This category is comprised of the integral parts, controlled entities, and political subdivision of Cambodia.

**2. International Organization**

Any international organization or wholly owned agency or instrumentality thereof will be treated as an Exempt Beneficial Owner.

**3. Central Bank**

This refers to the National Bank of Cambodia and all of its wholly-owned subsidiaries and International Representative Offices.

**4. Funds that Qualify as Exempt Beneficial Owners**

The following Entities shall be treated as Non-Reporting Cambodian Institutions and as exempt beneficial owners.

a) Broad Participation Retirement Fund
b) Narrow Participation Retirement Fund
c) Pension Fund of an Exempt Beneficial Owner

**5. Investment Entity Wholly Owned by Exempt Beneficial Owners**

An Entity that is a Cambodian Financial Institution solely because it is an Investment Entity, provided that each direct holder of an Equity Interest in the Entity is an Exempt Beneficial Owner, and each direct holder of a debt interest in such Entity is either a Depository Institution (with respect to a loan made to such Entity) or an Exempt Beneficial Owner.

**B. Deemed Compliant Foreign Financial Institutions (DCFFIs)**

If you are one of the following Financial Institutions below, you may qualified as a Non-Reporting Cambodian Financial Institutions that shall be treated as deemed Compliant Foreign Financial Institutions (DCFFIs) and are generally not required to register with the IRS or report U.S. Reportable Accounts, unless stated otherwise in Annex II of the IGA.

**1. Financial Institution with a Local Client Base**

A Financial Institution must meet all 10 conditions as stated in Annex II of the IGA before this exemption can be claimed.

**2. Local Bank**

A Financial Institution will be deemed as a Local Bank if it meets all 05 conditions as stated in Annex II of the IGA.

**3. Financial Institution with only Low-Value Accounts**

A Financial Institution is treated as having only Low-Value Accounts if it meets all 03 conditions as stated in Annex II of the IGA.

### 4. Qualified Credit Card Issuers

A Qualified Credit Card Issuer may be treated as a DCFFI if it meets all 02 conditions as stated in Annex II of the IGA.

### 5. Trustee-Documented Trust

A Trustee-Documented Trust is considered as a Non-Reporting Financial Institutions and is treated as deemed-compliant FFI for purposes of section 1471 of the U.S. Internal Revenue Code. A trust established under the laws of Cambodia to the extent that the trustee of the trust is a Reporting U.S. Financial Institution, Reporting Model 1 FFI, or Participating FFI and the trustee reports all information required to be reported pursuant to the Agreement as would be required if the trust were a Reporting Cambodian Financial Institution (including by following the applicable registration requirements on the IRS FATCA registration website).

### 6. Sponsored Investment Entities and Controlled Foreign Corporation

A Financial Institution is a Sponsored Investment Entity if the Financial Institution meets all 03 conditions as stated in Annex II of the IGA.

### 7. Sponsored Closely Held Investment Vehicles

A Financial Institution is a Sponsored Closely Held Investment Vehicles if the Financial Institution meets all 05 conditions as stated in Annex II of the IGA.

### 8. Investment Advisors and Investment Managers

When an investment advisor or investment manager falls within the scope of an Investment Entity, it would be considered a Non-Reporting Financial Institution if it is established in Cambodia solely because it (1) Renders investment advice to, and acts on behalf of, or (2) Manages portfolios for, and acts on behalf of, a customer for the purposes of investing, managing, or administering funds deposited in the name of the customer with an FI other than an Nonparticipating Financial Institutions.

### 9. Collective Investment Vehicles

A Collective Investment Vehicles (CIS) may qualify as Deemed-Compliant Foreign Financial Institution if it is established in Cambodia and is regulated as a collective investment scheme, provided that all of the interests in the CIS (including debt interests in excess of $50,000) are held by or through one or more exempt beneficial owners, active NFFEs, U.S. Persons that are not Specified U.S. Persons, or Financial Institutions that are not Nonparticipating Financial Institutions.

### 10. Special Rules

The following rules apply to an Investment Entity:

a) With respect to interests in an Investment Entity that is a collective investment vehicle described in paragraph 9 above of this section, the reporting obligations of any Investment Entity (other than a Financial Institution through which interests in the collective investment vehicle are held) shall be deemed fulfilled.

b) With respect to interests in:
   - An Investment Entity established in a Partner Jurisdiction that is regulated as a collective investment vehicle, all of the interests in which (including debt interests in excess of $50,000) are held by or through one or more exempt beneficial owners, Active NFFEs described in subparagraph B(4) of section VI of Annex I of the Agreement, U.S. Persons that are not Specified U.S. Persons, or Financial Institutions that are not Nonparticipating Financial Institutions; or
   - An Investment Entity that is a qualified collective investment vehicle under relevant U.S. Treasury Regulations; the reporting obligations of any Investment Entity that is a Cambodian Financial Institution (other than a Financial Institution through which interests in the collective investment vehicle are held) shall be deemed fulfilled.

c) With respect to interests in an Investment Entity established in Cambodia that is not described in paragraph 9 or subparagraph 10(b) above, consistent with paragraph 4 of Article 5 of the Agreement, the reporting obligations of all other Investment Entities with respect to such interests shall be deemed fulfilled if the information required to be reported by the first-mentioned Investment Entity pursuant to the Agreement with respect to such interests is reported by such Investment Entity or another person.


Non-Reporting FIs
Exempt Beneficial Owners
Government Entity
International Organization
Central Bank
Funds that Qualify as Exempt Beneficial Owners
Investment Entity wholly owned by Exempt Beneficial Owners
Broad Participation Retirement Fund
Narrow Participation Retirement Fund
Pension Fund of an Exempt Beneficial Owner
Deemed Compliant Financial Instituitions
Financial Institution with a Local Client Base
Local Bank
Financial Institution with only Low-Value Accounts
Qualified Credit Card Issuer
Trustee-Documented Trust
Sponsored Investment Entity and Controlled Foreign Corporation
Sponsored, Closely Held Investment Vehicle
Investment Advisors and Investment Managers
Collective Investment Vehicle
Special Rules